# មេរៀនទី៧៨៖ ព្រះយេស៊ូវបានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធមក

## កិច្ចការ ២៖១-២១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ **https://youtu.be/SDDMBAPE8TY**

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** **https://youtu.be/gjdcZG6m7oM**

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៤៖១៦-១៧ក** *"នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹង ប្រទានព្រះដ៏ជាជំនួយ១អង្គទៀត មកអ្នករាល់គ្នា ឲ្យបានគង់នៅជាមួយនៅអស់កល្បរៀងទៅ គឺជាព្រះវិញ្ញាណនៃសេចក្តីពិត "។*

**ចំរៀង** ( *យូធូបលីង* )៖

១. ពេលដែលព្រះវិញ្ញាណបរិសុទ្ធ https://youtu.be/RODHIMCRzw4

២. ខ្ញុំដឹងថា https://youtu.be/ywt-KvGIQcE

៣. ព្រះចាត់បុត្រា https://youtu.be/eDsWfEtrnS0

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«បាទ/ចាស ឬទេ »**



ចា/បាទ ទេ

១. ឲ្យកុមារអង្គុយជា ពីរ ឬបីក្រុម។

២.គ្រូត្រូវសួរសំណួរទាក់ទងទៅនឹងព្រះគម្ពីរ ដែលកុមារគ្រាន់តែឆ្លើយ បាទ/ចាស ឬក៏ទេ។

៣. កុមារតាមក្រុមនីមួយៗមិនអនុញ្ញាតឲ្យពិភាក្សាគ្នា ដើម្បីស្វែងរកចម្លើយនោះទេ។ ក្រុមណាដែលធ្វើ កាយវិការបញ្ជាក់ពីចម្លើយបានត្រូវច្រើនជាងគេ ក្រុមនោះជាអ្នកឈ្នះ។

៤. សំណួរអាចជា៖

ក. មនុស្សប្រុសដំបូងគេនៅក្នុង ព្រះគម្ពីរមានឈ្មោះ ថា អ័ដាម (បាទ/ចាស)

ខ. អាប្រាហាំសង់ទូកដ៏ធំមួយ(ទេ)

គ. យូណាស់បានចូល ទៅក្នុងពោះក្រពើដ៏ធំមួយ (ទេ)

ឃ. ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញនៅថ្ងៃអាទិត្យ (បាទ/ចាស)

ង. ព្រះអាចដើរនៅលើទឹក (បាទ/ចាស)

ច. ពេត្រុសបានព្យាបាលម្តាយក្មេកគាត់ឲ្យជា (ទេ)

ឆ.បន្ទាប់ពីព្រះយេស៊ូវបានត្រឡប់ទៅឋានសួគ៌វិញ តើទ្រង់បានបញ្ជូលព្រះវិញ្ញាណបរិសុទ្ធមក (បាទ/ចាស)

៥.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះវិញ្ញាណបរិសុទ្ធមានអំណាចដែលអាចជួយយើងបានគ្រប់រឿងទាំងអស់។

## ៤. ការណែនាំមេរៀន

តើអ្នកនឹងសប្បាយចិត្តដែរឬទេ ប្រសិនបើគ្រួសាររបស់អ្នកធ្វើដំណើរទៅកន្លែងណាមួយ ដោយមិនយកអ្នកទៅជាមួយនោះ? តើអ្នកចង់ឲ្យគេទុកអ្នកចោលឲ្យនៅតែឯងដែរឬទេ? តើអ្នកនឹងមានអារម្មណ៍បែបណា? នៅពេលដែលព្រះយេស៊ូវបានប្រាប់ពួកសិស្សទ្រង់ថា ព្រះអង្គនឹងត្រូវចាកចេញពីពួកគេឆាប់ៗនេះ តើអ្នកគិតថា ពួកសិស្សរបស់ព្រះអង្គមានអារម្មណ៍យ៉ាងណាដែរ? តើអ្នកគិតថា ពួកគេនឹងភ័យខ្លាចច្របូកច្របល់ ឬក៏ខឹង ដែរឬទេ?

យើងដឹងថា ព្រះយេស៊ូវនឹងមិនទុកឲ្យយើងនៅមើលថែខ្លួនយើងតែឯងនោះទេ។ ព្រះយេស៊ូវជ្រាបដឹងថា ពួកសិស្សរបស់ទ្រង់ត្រូវការជំនួយ ដើម្បីបំពេញព័ន្ធកិច្ចដែលទ្រង់បានដាក់សំរាប់ពួកគេ។ ដូច្នេះព្រះយេស៊ូវបានធ្វើការសន្យាដើម្បីបញ្ជូនអ្នកជំនួយឲ្យមក។ សាកទាយទៅមើលថា តើអ្នកជំនួយនោះគឺជានរណា? សូមឲ្យយើងរៀនពីអ្នកជំនួយនៅក្នុងមេរៀនថ្ងៃនេះ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវជ្រាបដឹងថា ដល់ពេលដែលទ្រង់ត្រូវត្រឡប់ទៅស្ថានសួគ៌វិញហើយ។ ប៉ុន្តែព្រះអង្គមិនចង់ឲ្យពួកសិស្សរបស់ទ្រង់កើតទុក្ខ ឬភ័យខ្លាចឡើយ។ ដូច្នេះព្រះយេស៊ូវបានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធទៅជួយពួកគេ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាវិញ្ញាណរបស់ព្រះ។ បន្ទាប់ពីព្រះយេស៊ូវ បានយាងទៅស្ថានសួគ៌វិញ មនុស្សជាច្រើនបានប្រារព្ធថ្ងៃបុណ្យសំរាកមួយដែលមានឈ្មោះថា **បុណ្យថ្ងៃទី៥០**។ មនុស្សមកពីជុំវិញពិភពលោកបានមកទីក្រុងយេរូសាឡឹម ដើម្បីប្រារព្ធពិធី បុណ្យថ្ងៃទី៥០។ មនុស្សនិយាយភាសាផ្សេងៗគ្នាជាច្រើន ប៉ុន្តែពួកគេទាំងអស់គ្នាមកក្រុងយេរូសាឡឹម ដើម្បីអរព្រះគុណព្រះជាម្ចាស់ចំពោះការប្រមូលផលដ៏ល្អរបស់ពួកគេ។

នៅថ្ងៃបុណ្យដ៏ពិសេស ពួកសិស្សបានមកជួបជុំគ្នានៅកន្លែងមួយ។ រំពេចនោះមានរឿងមួយបានកើតឡើង គ្មាននរណាម្នាក់ដឹងច្បាស់ទេថា វាកើតឡើងដោយរបៀបណា ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើពួកសិស្សរបស់ព្រះយេស៊ូវ។ ពួកគេបានលឺសំឡេងខ្យល់បក់គំហុកយ៉ាងខ្លាំង។ ពួកគេបានឃើញអណ្តាតភ្លើងតូចៗជាច្រើនមកសណ្ឋិតលើពួកគេគ្រប់ៗគ្នា។ ហើយក្នុងពេលដំណាលគ្នានោះ ពួកសិស្សរបស់ព្រះយេស៊ូវក៏បានចាប់ផ្តើមនិយាយភាសាដទៃផ្សេងៗគ្នាដែរ។ វាជាការអស្ចារ្យ ពីព្រោះពួកសិស្សមិនចេះនិយាយភាសាទាំងអស់នោះទេ។ តែព្រះវិញ្ញាណបរិសុទ្ធបានជួយពួកសិស្សឲ្យនិយាយភាសាដទៃទាំងអស់នោះបាន។ ហើយមនុស្សទាំងអស់ ដែលធ្វើដំណើរមកដល់ទីក្រុងយេរូសាឡិមបានចូលរួមអបអរសាទរ ពិធីបុណ្យថ្ងៃទី៥០ ហើយបានលឺពួកសិស្សនិយាយភាសារបស់ខ្លួន។ មនុស្សមួយចំនួនមិនបានយល់ថា ព្រះវិញ្ញាណបរិសុទ្ធដ៏មានឫទ្ធានុភាពបានយាងមកឯពួកសិស្ស ហើយបានធ្វើឲ្យរឿងនេះកើតឡើងនោះទេ។ ពួកគេគិតថា ពួកសិស្សស្រវឹងស្រា។

ដោយមានជំនួយរបស់ព្រះវិញ្ញាណបរិសុទ្ធ ពួកសិស្សមានចិត្តក្លាហាន ចែកចាយពីព្រះយេស៊ូវទៅកាន់មនុស្សជាច្រើនទៀត។ ពួកសិស្សចង់ឲ្យមនុស្សគ្រប់គ្នាស្គាល់ព្រះយេស៊ូវថា ជាព្រះគ្រីស្ទ ហើយស្គាល់ពួកគេថា ជាសិស្សរបស់ព្រះយេស៊ូវ។ ពេត្រុសជាសិស្សម្នាក់របស់ព្រះយេស៊ូវ គាត់បានក្រោកឈរឡើងដោយចិត្តក្លាហាននៅកន្លែងដែលមនុស្សម្នាទាំងអស់អាចមើលឃើញគាត់។ ពេត្រុសបានប្រាប់មនុស្សទាំងអស់នោះថា ពួកគេបានទទួលបានព្រះពរដ៏អស្ចារ្យមកពីព្រះ។ ពួកគេបានអធិប្បាយប្រាប់មនុស្សគ្រប់

គ្នាអំពី ព្រះយេស៊ូវ ហើយបានធ្វើឲ្យពួកគេស្គាល់ព្រះវិញ្ញាណបរិសុទ្ធ ដែលកំពុងតែនៅជាមួយពួកគេឥឡូវនេះ។ មនុស្សទាំងអស់បានស្តាប់លឺដោយត្រចៀក និងដោយចិត្តរបស់ពួកគេពីអ្វី ដែលពេត្រុសបានចែកចាយ។ ហើយមានមនុស្សរាប់ពាន់នាក់បានទទួលជឿព្រះយេស៊ូវនៅក្នុងថ្ងៃនោះ។ ព្រះវិញ្ញាណបរិសុទ្ធគឺពិតជាអ្នកជំនួយដ៏អស្ចារ្យ។

ព្រះវិញ្ញាណបរិសុទ្ធដ៏មានអំណាចដូចគ្នានេះ គឺកំពុងគង់នៅជាមួយនឹងមនុស្សគ្រប់គ្នា ដែលជឿលើព្រះយេស៊ូវ ហើយផ្តល់ឱ្យយើងនូវកម្លាំង ភាពក្លាហាន និងការកំសាន្តចិត្តផងដែរ! ព្រះយេស៊ូវបានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធមករកយើង ដោយសារទ្រង់ស្រឡាញ់យើង ហើយចង់ឱ្យយើងមានភាពរឹងមាំ និងក្លាហាន។ យើងរាល់គ្នាជាកូនរបស់ព្រះអង្គ។ ព្រះថៃរក្សាយើងដោយទ្រង់បានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធដ៏មានគ្រប់ទាំងព្រះចេស្តាមកកាន់យើង។ យើងមានអំណាចដោយសារ ព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងយើងគឺមានអំណាច។

## ៦. សំនួរពិភាក្សា

១.តើព្រះយេស៊ូវបានបញ្ជូនអ្នកណា ដែលជាជំនួយបន្ទាប់ពីព្រះអង្គបានយាងទៅស្ថានសួគ៌វិញ? *(ព្រះវិញ្ញាណបរិសុទ្ធ)*

២. ហេតុអ្វីបានជាព្រះវិញ្ញាណបរិសុទ្ធមានអំណាច? *(ពីព្រោះព្រះវិញ្ញាណបរិសុទ្ធជាព្រះវិញ្ញាណរបស់ព្រះ)*

៣. តើមានការអស្ចារ្យអ្វីបានកើតឡើងបន្ទាប់ពី ព្រះវិញ្ញាណបរិសុទ្ធបានសណ្ឋិតលើពួកសិស្ស? *(ពួកសិស្សនិយាយភាសាដទៃផ្សេងៗ ហើយពួកគេមានចិត្តក្លាហានក្នុងការនិយាយអំពីព្រះយេស៊ូវ)*

៤.ហេតុអ្វីបានជាអ្នកគិតថា វាសំខាន់នៅពេលដែល ព្រះយេស៊ូវបញ្ជូនព្រះវិញ្ញាណបរិសុទ្ធមកកាន់យើង? *(យើងត្រូវការជំនួយពីព្រះដើម្បីដើរតាមព្រះយេស៊ូវ! ព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យរស់តាមផ្លូវដែលព្រះយេស៊ូវចង់ឲ្យយើងរស់តាមផ្លូវទ្រង់)*

៥. តើព្រះវិញ្ញាណបរិសុទ្ធកំពុងគង់ជាមួយអ្នកដែរឬទេ? *(ចាំ/បាទ ព្រះវិញ្ញាណបរិសុទ្ធ គង់ជាមួយខ្ញុំពីព្រោះខ្ញុំជឿលើព្រះយេស៊ូវ)*

## ៧. ល្បែងកំសាន្ត «បញ្ជូនប៉េងប៉ោង»

**សម្ភារៈដែលត្រូវការ៖** ប៉េងប៉ោងមួយចំនួន និងកន្ត្រក១



១. ចែកកុមារជា ២ ក្រុម។

២. ឲ្យសមាជិកក្រុមចាប់ដៃគូរពីរៗនាក់ ហើយឲ្យប៉េងប៉ោងទៅដៃគូរនីមួយៗ។

៣. ដៃគូរនីមួយៗត្រូវដាក់ប៉េងប៉ោងនៅចន្លោះដៃពួកគេទាំងពីរ(ដូចរូប) ហើយរត់យកប៉េងប៉ោងទៅដាក់នៅក្នុងកន្ត្រក។

៤. គូរដែលអាចបញ្ចូលប៉េងប៉ោងដាក់ចូលទៅក្នុងកន្ត្រកបានមុនគេ ក្រុមពួកគេនឹងទទួលបានមួយពិន្ទុ។

៥. ឲ្យដៃគូរបន្ទាប់បន្តលេងល្បែងនេះ។ បន្តលេងរហូតដល់ដៃគូរនីមួយៗលេងបានគ្រប់គ្នា។ ក្រុមណាដែលដែលទទួលបានពិន្ទុច្រើនជាងគេ ក្រុមនោះជាអ្នកឈ្នះ។ ប្រសិនបើប៉េងប៉ោងជ្រុះពួកគេត្រូវត្រឡប់មកទីវិញ ហើយចាប់ផ្តើមលេងម្តងទៀត។

៦.តាមរយៈល្បែងនេះ កុមារនិងរៀនបានពីការជួយគ្នាទៅវិញទៅមក ដូចជាព្រះវិញ្ញាណបរិសុទ្ធគឺជាអ្នកជួយដ៏អស្ចារ្យ ដែលតែងតែជួយដល់យើងគ្រប់គ្នាៗគ្រប់ពេលវេលា។

## ៨. ខគម្ពីរចងចាំ

**យ៉ូហាន ១៤៖១៦-១៧** *“នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានព្រះដ៏ជាជំនួយ១អង្គទៀត មកអ្នករាល់គ្នាឲ្យបានគង់នៅជាមួយនៅអស់កល្បរៀងទៅ គឺជាព្រះវិញ្ញាណនៃ សេចក្ដីពិត ”។*

## ៩. ហាត្ថកម្ម «មកុដនៃព្រះវិញ្ញាណបរិសុទ្ធ»

សម្ភារៈដែលត្រូវការ៖ ក្រដាស កូល័រទៀន កន្ត្រៃ ការ ស្កុត ឬដែកកិប

១. ឱ្យកុមារកាត់ក្រដាសធ្វើជាអណ្ដាតភ្លើង ដោយផាត់ពណ៌លើក្រដាសឬកាត់ក្រដាសពណ៌ធ្វើជាអណ្ដាតភ្លើងក៏បាន។

២. បិតអណ្ដាតភ្លើងដែលមានទំហំផ្សេងៗគ្នា ដាក់រួមគ្នាដោយធ្វើជាអណ្ដាតភ្លើងធំតែមួយ ហើយបិតវាទៅលើក្រដាសវែងដែលបានកិបជាប់គ្នាហើយ។

៣. គ្រូអាចជួយកាត់ក្រដាស ហើយកិបជាប់គ្នាឲ្យបានវែងល្មមនឹងក្បាលកុមារដើម្បីធ្វើជាមកុដ។

៤. ពន្យល់ដល់កុមារថា អ្នកជឿលើព្រះយេស៊ូវទាំងអស់ គឺមានព្រះវិញ្ញាណបរិសុទ្ធដ៏មានអំណាចគង់នៅក្នុងពួកគេ ដើម្បីឱ្យពួកគេមានកំម្លាំង និងភាពក្លាហាន!





## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ប្រសិនបើអ្នកអាន **កិច្ចការ ៣៖១២–២០** អ្នកអាចឃើញថា អំណាចនៃព្រះវិញ្ញាណបរិសុទ្ធបានផ្លាស់ប្ដូរពេត្រុសយ៉ាងខ្លាំង។ ពេត្រុសធ្លាប់បដិសេធព្រះយេស៊ូវ ប៉ុន្តែឥឡូវនេះបានចែកចាយដំណឹងល្អអំពីព្រះយេស៊ូវយ៉ាងក្លាហាន។ តើព្រះវិញ្ញាណបរិសុទ្ធបានផ្លាស់ប្ដូរអ្នកដោយរបៀបណា? តើអ្នកនឹងពឹងផ្អែកលើអំណាចនៃព្រះវិញ្ញាណបរិសុទ្ធដើម្បីរស់នៅដោយក្លាហាន ហើយចែកចាយយ៉ាងក្លាហានអំពីសេចក្ដីជំនឿរបស់អ្នកដោយរបៀបណា? ចូរអធិស្ឋានដោយសុំព្រះវិញ្ញាណបរិសុទ្ធឲ្យជួយផ្លាស់ប្ដូររបៀបរស់នៅរបស់អ្នកឲ្យក្លាយជាមនុស្សក្លាហានសម្រាប់ព្រះគ្រីស្ទយេស៊ូវ។

# “ម្កុដនៃព្រះវិញ្ញាណបរិសុទ្ធ”



